ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា [i] បានកំណត់ថា តុលាការនេះត្រូវតែគោរពតាមមាត្រដ្ឋានដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និង នយោបាយ ( ICCPR) នៃអង្គការសហប្រជាជាតិ ដែលជាទូទៅត្រូវបានស្គាល់ថាជាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដើម្បីការពារជនជាប់ចោទដែលប្រព្រឹត្តបទឧក្រិដ្ឋពីការផ្តន្ទាទោសដោយគ្មានមូលដ្ឋានច្បាប់ច្បាស់លាស់ [ii] ។ សិទ្ធិទាំងនេះរួមមាន សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និង ជាសាធារណៈពីសំណាក់តុលាការឯករាជ្យ និង មិនលំអៀង ដែលត្រូវ បានបង្កើតឡើងដោយច្បាប់។ សិទ្ធិទាំងអស់នោះក៏បានរួមបញ្ចូល សិទ្ធិទទួលបានការសន្មតជាមុនថាគ្មានទោសរហូតដល់មានការបង្ហាញឱ្យឃើញថាមានទោស សិទ្ធិទទួលបានជំនួយមេធាវី និង សិទ្ធិមានពេលវេលាគ្រប់គ្រាន់ដើម្បីរៀបចំជាមួយមេធាវីការពារក្តីរបស់ខ្លួន សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យាពេល សិទ្ធិមានវត្តមានក្នុងសវនាការ និង សាកសួរសាក្សី និង សិទ្ធិមិនត្រូវបានបង្ខំឲ្យផ្តល់សក្ខីកម្មដាក់បន្ទុកមកលើខ្លួនឯង។ គំនូសតាងខាងក្រោមបានរៀបរាប់ពីសិទ្ធិចំនួន ដែលត្រូវបានជួបប្រទះញឹកញាប់បំផុតនៅក្នុងសំណុំរឿង ០០២/០១ ដែលមានជនជាប់ចោទ **នួន ជា** និង ជនជាប់ចោទ **ខៀវ សំផន**។

<u>**ប្រភពច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលពាក់ព័ន្ធ៖**</u>

- ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា
- វិធានផ្ទៃក្នុង (វគ្គ៨)
- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- អនុសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និង នយោបាយ។

| សិទ្ធិ | បទដ្ឋានគតិយុទ្ធដែលប្រើប្រាស់នៅ អ.វ.ត.ក | បញ្ហានៅ អ.វ.ត.ក | ព័ត៌មាននៃការឃ្លាំមើលសាលាក្តីខ្មែរក្រហម |
|---|---|---|---|
| **សិទ្ធិមានវត្តមាន៖** សិទ្ធិមានវត្តមាននៅក្នុងសវនាការរបស់ជនជាប់ចោទ និង ការពារក្តីដោយខ្លួនគេផ្ទាល់ ឬ ក្រោមជំនួយរបស់មេធាវីការពារក្តី | មាត្រា៣៥ នៃច្បាប់ អ.វ.ត.ក (ដ) និង វិធានផ្ទៃក្នុង ៨១(១) ។ សូមមើល មាត្រា១៤.៣(ដ) អនុសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និង | ការចូលរួមដ៏មានប្រសិទ្ធិភាពរបស់ជនជាប់ចោទក្នុងសំណុំរឿង០០២/០១ គឺកំពុងកើតមាននូវបញ្ហាសារជាថ្មីជាពិសេសគឺការផ្តល់នូវពេលវេលាបន្តិចបន្តួចដើម្បីឲ្យជនជាប់ចោទ **នួន ជា** និង **អៀង សារី** មានវត្តមាននៅក្នុងបន្ទប់ | របាយការណ៍លេខ១៤ លេខ៣២ លេខ ៤៩ លេខ៣៨ លេខ៣៦ លេខ៦៧ លេខ៦៥ លេខ៥២ លេខ២៣ |

| | | | |
|---|---|---|---|
| ដែលពួកគេបានជ្រើសរើស | នយោបាយ | សវនាការក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី។<br>ក្រុមមេធាវីការពារក្ដីឲ្យជនជាប់ចោទ **អៀង សារី** បានសង្កត់ធ្ងន់ពីសារៈសំខាន់នៃវត្តមានរបស់ជនជាប់ចោទនៅក្នុងបន្ទប់សវនាការ ដោយបាន បន្ថែមថា ការកំហិតលទ្ធភាពរបស់ជនជាប់ចោទក្នុងការតទល់ជាមួយសាក្សី និង អ្នកជំនាញសំខាន់ៗ តាមរយៈវីដេអូគឺមិនស្របតាមសិទ្ធិរបស់ជនជាប់ចោទក្នុងការមានវត្តមាននៅក្នុងតុលាការនោះទេ។<br>កិច្ចខិតខំប្រឹងប្រែងរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការសម្របទៅតាមតម្រូវការសុខភាពរបស់ជនជាប់ចោទដើម្បីធានាដល់ការចូលរួមរបស់ពួកគេនៅក្នុងសវនាការរួមមាន ការផ្ដល់ការសម្របសម្រួលនៅក្នុងបន្ទប់ឃុំ និង អនុញ្ញាតឱ្យជនជាប់ចោទតាមដានកិច្ចដំណើរការនីតិវិធីតាមរយៈវីដេអូនៅក្នុងបន្ទប់ឃុំ នៅពេលដែលស្ថានភាពសុខភាពរបស់ពួកគេមិនសូវល្អ។ តែទោះជាយ៉ាងណា វិធានការទាំងនេះ ត្រូវទទួលរងនូវការរិះគន់ពីសំណាក់មេធាវីការពារក្ដី។ | |
| **កាយសម្បទាក្នុងការចូលរួមសវនាការ៖** សវនាការដាច់ដោយឡែកជាច្រើនត្រូវបានធ្វើឡើង ស្ដីពី កាយសម្បទាក្នុងការចូលរួមការសវនាការ | វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក លេខ៣២ និង ៨៩។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (១៩៩៣) មាត្រា៣១ | ជាកិច្ចដំបូង ជនជាប់ចោទនៃសំណុំរឿង០០២ រួមមាន លោកស្រី **អៀង ធីរិទ្ធិ** (អាយុ៨១ឆ្នាំ) លោក **អៀង សារី** (អាយុ៨៧ឆ្នាំ) លោក **នួន ជា** (អាយុ៨៦ឆ្នាំ)និង លោក **ខៀវ សំផន** (អាយុ៨២ឆ្នាំ)។ មានការលើកឡើងពី | របាយការណ៍ពិសេសរបស់គំនិតផ្តួចផ្តើមយុត្តិធម៌អន្តរជាតិនៅអាស៊ី(AIJI) ប្រចាំខែវិច្ឆិកា និង ធ្នូ ឆ្នាំ២០១២ |

| | | | |
|---|---|---|---|
| ទាក់ទងទៅនឹងសុខភាព និង អាយុរបស់ជនជាប់ចោទក្នុងសំណុំរឿង ០០២។ | (៣)។ វិធានផ្ទៃក្នុងលេខ៨១(៤) និង ៨១(៥) | ការការព្រួយបារម្ភដ៏ធ្ងន់ធ្ងរអំពីបញ្ហាកាយសម្បទាដើម្បីចូលរួមសវនាការរបស់ពួកគេ ជាពិសេសបញ្ហាអាយុ និង បញ្ហាសុខភាព។ លោកស្រី **អៀង ធីរិទ្ធ** ជាជនជាប់ចោទដំបូងគេដែលត្រូវបានរកឃើញថាមិនមានកាយសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមការសវនាការ ដោយសារតែស្ថានភាពផ្លូវចិត្តរបស់គាត់។ លោក **អៀង សារី** ត្រូវបានរកឃើញថា មានកាយសម្បទាសមស្របសម្រាប់ចូលរួមការជំនុំជម្រះក្តី ដោយផ្អែកលើការរកឃើញរបស់អ្នកជំនាញផ្នែកជរាពាធ។ បញ្ហានៃការចូលរួមដ៏មានប្រសិទ្ធិភាពរបស់ជនជាប់ចោទ **អៀង សារី** នៅក្នុងកិច្ចដំណើរការនីតិវិធីនេះ ត្រូវបានគេលើកយកមកពិភាក្សាដូចជា បញ្ហានៃការធ្លាក់ដុនដាបនៃសុខភាពរបស់ជនជាប់ចោទ ប៉ុន្តែ មិនទាន់បានដោះស្រាយនៅឡើយទេ ខណៈដែលគាត់បានស្លាប់នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៣។ | របាយការណ៍លេខ២ លេខ៤ លេខ៤២ លេខ៤៣ លេខ៤៤ លេខ៤៥ លេខ៤៩ លេខ៥០ និង លេខ៥១។ |
| **សិទ្ធិទទួលបានការជំនុំជម្រះសមហេតុផល៖** អង្គជំនុំជម្រះតុលាការកំពូលបានកំណត់សិទ្ធិទទួលបានការជំនុំជម្រះសមហេតុផលថា៖ “សេចក្តីសម្រេចរបស់តុលាការត្រូវតែបង្ហាញពីទង្វើរបស់តុលាការ។ ជា | វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក លេខ៦៦ និង អនុសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និង នយោបាយ មាត្រា១៤(៣) | ជាញឹកញាប់ អង្គជំនុំជម្រះសាលាដំបូង បានបរាជ័យក្នុងការផ្តល់នូវសាលក្រមដែលសមហេតុផល ដោយជ្រើសរើសធ្វើការសម្រេចចិត្តតាមករណីផ្សេងៗ។ វាគឺជាភស្តុតាងមួយ នៅពេលដែលអង្គជំនុំជម្រះសាលាដំបូងបានបរាជ័យក្នុងការសម្រេចឲ្យច្បាស់លាស់ ថាតើភាគីអាចសាកសួរសាក្សីដើម្បីធ្វើអត្ថាធិប្បាយលើសេចក្តីថ្លែងការណ៍ | របាយការណ៍លេខ២៤ លេខ៣៦ លេខ៥៣ និង លេខ៥៦ |

| | | | |
|---|---|---|---|
| ការគោរព វាគឺជាការចាំបាច់សម្រាប់ការសម្រេចចិត្តរបស់តុលាការដើម្បីចាត់ចែងបញ្ហាផ្លូវច្បាប់ មុនពេលវាមានលក្ខណៈច្បាស់លាស់មួយ”។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់បន្ថែមទៀតថា សិទ្ធិទទួលបានការសម្រេចសមហេតុផល “ជាផ្នែកមួយនៃសិទ្ធិទទួលបានការជំនុំជម្រះ”។ | | ដែលធ្វើឡើងដោយសាក្សីដ៏សំខាន់នាពេលអនាគតដែរឬទេ។<br>ក្រុមមេធាវីការពារក្តីបានអះអាងថា គ្មាន សាក្សីណាម្នាក់ រួមទាំងសាក្សីជំនាញ **ភីលីប ស្សត** ( Philip Short) និង **អេលីហ្សាបែត បែកខ័រ** (Elizabeth Becker) គួរតែត្រូវបានកោះហៅ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងមិនចេញសេចក្តីសម្រេចពេញលេញ និង សមហេតុផលចំពោះវិសាលភាពនៃការជំនុំជម្រះនេះ។<br>នៅក្នុងការប្រឈមនឹងការបន្តការខ្វះខាតនៃការវិនិច្ឆ័យសមហេតុផលពីអង្គជំនុំជម្រះសាលាដំបូង មេធាវីអន្តរជាតិការពារក្តីឲ្យលោក **ខៀវ សំផន** គឺលោក **អាកទួរ វ៉េកគែន** (Arthur Vercken) បានជំទាស់ទៅនឹងការបន្តនៃកិច្ចដំណើរការនីតិវិធី ដោយមិនមាន ការសម្រេចចិត្តជាលាយល័ក្ខអក្សរស្តីពីដំណោះស្រាយនៃសំណុំរឿង០០២/០១ ពីអង្គជំនុំជម្រះសាលាដំបូងនោះទេ។ | |
| **សិទ្ធិរក្សាភាពស្ងៀមស្ងាត់៖** សិទ្ធិរបស់ជនជាប់ចោទក្នុងការបដិសេធមិនធ្វើអត្ថាធិប្បាយ ឬ ឆ្លើយនៅពេលត្រូវបានគេចោទសួរ | វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក មាត្រា១(ដ) និង អនុសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និង នយោបាយ មាត្រា១៤(៣) និង សន្ធិសញ្ញ | លោក **ខៀវ សំផន** បានបញ្ជាក់ថា លោកមិនត្រូវបានត្រៀមដើម្បីឆ្លើយនូវសំណួរទាក់ទងនឹងប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមឡើយ។ បើទោះបីជា ដំបូងឡើយ គាត់និយាយថា គាត់នឹងផ្តល់សក្ខីកម្មពេលបញ្ចប់សវនាការ | របាយការណ៍លេខ៥ លេខ៦ លេខ៧ លេខ៨ លេខ៩ លេខ ១១ លេខ១២ លេខ១៣ លេខ១៥ លេខ១៩ លេខ៣៩ |

| | | | |
|---|---|---|---|
| | ទីក្រុងរ៉ូម ស្តីពីតុលាការឧក្រិដ្ឋកម្មអន្តរជាតិ (Rome Statue of the International Criminal Court) មាត្រា៥៥ | ខណៈដែលភស្តុតាងទាំងអស់ត្រូវបានលើកយកមកបង្ហាញ។ លោក **ខៀវ សំផន** បានប្រាប់តុលាការថា គាត់បានសម្រេចចិត្តដើម្បី  អនុវត្តសិទ្ធិនៅស្ងៀមរបស់គាត់ ដោយលើកឡើងថា មានការបំពានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់គាត់។<br>ជុំវិញការកាត់ក្តីនៃសំណុំរឿង០០២/០១ លោក **នួន ជា** បានឆ្លើយតបទៅសំណួរដែលបានចោទសួរឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី និង ចៅក្រមអង្គជំនុំជម្រះសាលាដំបូង ប៉ុន្តែ នៅទីបំផុត គាត់បានសម្រេចចិត្ត នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៣ ដោយលើកឡើងពីការខ្វះទំនុកចិត្តរបស់គាត់ មកលើសមត្ថភាពរបស់តុលាការ ក្នុងការគោរពគោលការណ៍នៃការជំនុំជម្រះដោយយុត្តិធម៌។ គាត់នឹងមិនឆ្លើយតបទៅនឹងសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណី និង សហព្រះរាជអាជ្ញាទៀតហើយ ។<br>ការលើកឡើងពីការប្រែប្រួលរបស់ជនជាប់ចោទ រវាងការឆ្លើយតបទៅនឹងសំណួរ និង ការទាមទារសិទ្ធិរបស់ពួកគេដើម្បីរក្សាភាពស្ងៀមស្ងាត់ ធ្វើឲ្យសហព្រះរាជអាជ្ញាធ្វើការស្នើសុំទៅកាន់អង្គជំនុំជម្រះសាលាដំបូង ដើម្បីពិចារណាពីផ្នែកមិនល្អ ឬ) ការពិចារណាដែលដកចេញពីភាពស្ងៀមស្ងាត់ ប្រឆាំងនឹង (ជនជាប់ចោទ ។ រឿងនេះត្រូវ | លេខ៥៤ លេខ៦០ លេខ៦៧ លេខ៦៨ |

| | | | |
|---|---|---|---|
| | | បានជំទាស់យ៉ាងខ្លាំងពីក្រុមមេធាវីការពារក្តី ដោយបានអះអាងថា ការធ្វើដូច្នេះនឹងធ្វើអោយសិទ្ធិប្រែជាគ្មានន័យ និងបានស្នើសុំអង្គជំនុំជម្រះពិចារណាបញ្ហានេះ ជាផ្នែកមួយនៃការពិភាក្សាចុងក្រោយរបស់ខ្លួន។ | |

[i] Available here, The Law on the Establishment of the Extraordinary Chambers

[ii] The Extraordinary Chambers shall exercise their jurisdiction in accordance with international standards of justice, fairness and due process of law, as set out in Articles 14 and 15 of the 1966 International Covenant on Civil and Political Rights, to which Cambodia is a party. In the interest of securing a fair and public hearing and credibility of the procedure, it is understood that representatives of Member States of the United Nations, of the Secretary-General, of the media and of national and international non-governmental organizations will at all times have access to the proceedings before the Extraordinary Chambers. Any exclusion from such proceedings in accordance with the provisions of Article 14 of the Covenant shall only be to the extent strictly necessary in the opinion of the Chamber concerned and where publicity would prejudice the interests of justice.